## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក- (អ.ជ.ស.ដ)

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** (ឧបសម្ព័ន្ធសម្ងាត់)

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ដ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 01-Mar-2011, 14:26
CMS/CFO: Ly Bunloung

---

## សេចក្ដីបញ្ជាក់អំពីសាក្សី និងអ្នកជំនាញដែលបានស្នើឡើង

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក សា សូវ៉ាន

លោក Jacques VERGES

លោក Philippe GRECIANO

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម Silvia CARTWRIGHT

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖
មេធាវី ពេជ អង្គ
មេធាវី Elisabeth SIMONNEAU FORT

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. ស្របតាមដីការបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ (“ដីកា”) ដែលបានចេញដោយអនុវត្តតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង (“វិធាន”) ភាគីត្រូវប្រគល់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ នូវៈ (១) អត្ថបទសង្ខេបអង្គហេតុដែលសាក្សីនីមួយៗត្រូវដាក់ (២) អត្ថបទសង្ខេបរបស់អ្នកជំនាញដែលបានស្នើឡើង (៣) ចំណុចទាំងឡាយនៃដីកាបញ្ជូនរឿងទៅជម្រះពាក់ព័ន្ធទៅនឹងចម្លើយដែលផ្តល់ដោយសាក្សី និងអ្នកជំនាញនីមួយៗ។[1]

២. កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ លោក ខៀវ សំផន ត្រូវបានជូនដំណឹងអំពីបញ្ជីឈ្មោះសាក្សី ឈ្មោះអ្នកជំនាញ និងឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា[2]ជាភាសាបារាំង ហើយលោក ខៀវ សំផន បានដាក់បញ្ជីឈ្មោះរបស់ខ្លួនកាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។[3]

៣. ពេលនេះ លោក ខៀវ សំផន សូមផ្តល់ព័ត៌មានមួយចំនួន ដែលពាក់ព័ន្ធទៅនឹងធាតុផ្សំនៃភ័ស្តុតាង។ គាត់សូមរំលឹកសាជាថ្មីម្តងទៀតថា បន្ទុកនៃភ័ស្តុតាងធ្លាក់ទៅលើសហព្រះរាជអាជ្ញាតែមួយគត់។

---

[1] ដីកាដែលមានគោលដៅដាក់នូវឯកសារភ័ស្តុតាងក្នុងក្របខណ្ឌនៃការត្រៀមរៀបចំសវនាការ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9 (“ដីកា”) កថាខណ្ឌ ៦។

[2] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់ដោយសហព្រះរាជអាជ្ញា ដោយអនុវត្តតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង រួមមានឧបសម្ពន្ធសម្ងាត់ ១, ២, ៣, ៣ ក, ៤ និង ៥។ ឯកសារលេខ E9/4។ បកប្រែថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។

[3] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E9/4/6។ សំណៅជាភាសាខ្មែរនឹងត្រូវបានដាក់នៅពេលដែលអាចធ្វើទៅបាន ស្របទៅនឹងលិខិតជូនដំណឹងអំពីវិធានការណ៍របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការឆ្លើយតបទៅនឹងសំណើសុំពន្យារពេលវេលា ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ ឯកសារលេខ E9/6/1។

៤. លោក ខៀវ សំផន សង្កត់ធ្ងន់ទៅលើការរំលោភលើសិទ្ធិជាសារវន្តរបស់គាត់[4] ដោយហេតុថា រហូតមកដល់ដំណាក់កាលនេះ រូបគាត់នៅតែពុំមានលទ្ធភាពអាចដឹងឲ្យបានច្បាស់ ថាតើរូបគាត់ត្រូវការពារខ្លួនគាត់ទល់នឹងភ័ស្តុតាងចោទប្រកាន់ណាខ្លះ ជាពិសេស ដោយយោងទៅលើភាពខ្វះចន្លោះនៃកិច្ចការងាររបស់សហព្រះរាជអាជ្ញានោះ។ មេធាវីការពាររបស់គាត់សូមរក្សាសិទ្ធិផ្តល់សេចក្តីបញ្ជាក់នានានៅពេលក្រោយ ក្នុងអំឡុងនៃនីតិវិធី ដើម្បីពង្រឹងជំហរការពាររបស់ខ្លួន ដោយហេតុអយ្យការពុំបានផ្តល់ព័ត៌មានប្រាកដប្រជាដល់រូបគាត់ឡើយ។

៥. ការផ្តល់អត្ថបទសង្ខេបនៃព័ត៌មានដែលផ្តល់ដោយសាក្សី និងអ្នកជំនាញដែលត្រូវបានជ្រើសរើសដោយមេធាវីការពារនៅក្នុងលក្ខខណ្ឌដ៏បំពានបែបនេះ មានលក្ខណៈអយុត្តិធម៌ និងគ្រោះថ្នាក់ទាំងស្រុងដល់កិច្ចការងារស្វែងរកយុត្តិធម៌។

៦. អត្ថបទសង្ខីកម្មសង្ខេប (ឧបសម្ពន្ធ ១) និងឯកសារកោសល្យវិច័យ (ឧបសម្ពន្ធ ២) ពិតជាមានលក្ខណៈ**មិនពេញលេញ** និងមានលក្ខណៈ**បណ្តោះអាសន្ន** មិនអាចប្រកែកបាន ក្នុងការផ្តល់ឯកសារបន្ថែមដល់អង្គសវនាការ។

៧. តាមរបៀបនេះ អត្ថបទសង្ខេបទាំងនេះគ្រាន់តែបានផ្តល់ព័ត៌មានស្តីអំពីរបៀបទូទៅនៃអន្តរាគមន៍ដែលបានស្នើឡើង ហើយមិនបានធ្វើការបកស្រាយលម្អិតអំពីអត្ថន័យនៃអន្តរាគមន៍ទាំងនេះឡើយ។[5] ហេតុដូច្នេះ ចំណុចទាំងឡាយនៃដីកាបញ្ជូនរឿងទៅជម្រះដែលសាក្សី និងអ្នក

[4] លោក ខៀវ សំផន បានបង្ហាញថា **ការអនុវត្តវិធាន ៨០ បានរំលោភលើសិទ្ធិជាសារវន្តរបស់គាត់៖ សិទ្ធិទទួលបាននូវសច្ចធារណ៍និរទោស ដែលតាមរយៈគោលការណ៍នេះ បន្ទុកនៃភ័ស្តុតាងដែលបញ្ជាក់អំពីពិរុទ្ធភាពរបស់គាត់ ធ្លាក់ទៅលើអយ្យការ។ សិទ្ធិរបស់គាត់ក្នុងការទទួលបាននូវពេលវេលា និងលក្ខណៈគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំការពារក្តី ប្រកបដោយសមភាពពេញលេញ។ សិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់សេចក្តីដោយគ្មានភាពយឺតយ៉ាវហួសហេតុ។** សូមពិនិត្យមើលសំណើសុំពន្យារពេលក្នុងការដាក់ឯកសារភ័ស្តុតាង ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១។ ឯកសារលេខ E9/6។

[5] គួរកត់សម្គាល់ថា លោក ខៀវ សំផន ពុំបានផ្តល់នូវអត្ថបទសង្ខេបនៃចម្លើយសាក្សីដែលបានរៀបរាប់ដោយសហព្រះរាជអាជ្ញាដូចមានរាយឈ្មោះក្នុងបញ្ជី នៃឧបសម្ពន្ធ១ ស្ទួន។ ជាក់ស្តែង ការផ្តល់នូវព័ត៌មាននេះ ពុំមានកម្មវត្ថុឡើយ ដោយហេតុថាបញ្ជីឈ្មោះនេះ ត្រូវបានធ្វើឡើងតែក្នុងគោលដៅដើម្បីធានាថា គេអាចធ្វើការសាកសួរយកចម្លើយពេញ

ជំនាញត្រូវធ្វើការផ្តល់ចម្លើយ មានលក្ខណៈគ្រាន់តែជាការចង្អុលបង្ហាញតែប៉ុណ្ណោះ។

៨. ទិន្នន័យដែលបានបញ្ចោក់នៅក្នុងឧបសម្ព័ន្ធ ១ និង ២ ក្នុងតារាង "*ប្រភេទនៃអង្គហេតុដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជម្រះ*" យោងទៅលើចំណុចទាំងឡាយនៃ**ដីកាដំណោះស្រាយ**[6] តែមិនមែនយោងទៅលើ*តារាងស្តីពីប្រភេទផ្សេងៗគ្នានៃអង្គហេតុ* ដែលបានដាក់ដោយអង្គជំនុំជម្រះនោះទេ។[7]

៩. ជាទីបញ្ចប់ លោក ខៀវ សំផន លើកឡើងជាថ្មីអំពី**កាតព្វកិច្ច** របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជ្រើសតាំងជនដែលពុំមែនជាភាគីនៃរឿងក្តី (*Amicus Curiae*) ដើម្បីធានានូវសុវត្ថិភាពគតិយុត្តិ និងការកាត់សេចក្តីប្រកបដោយយុត្តិធម៌។ ជាក់ស្តែង វាជាការ**ចាំបាច់**ក្នុងការធានាឲ្យបាននូវឯករាជ្យភាព ក៏ដូចជា**តម្រូវការ**ក្នុងការស្វែងរកការពិត ដើម្បីជៀសវៀងកុំឲ្យមានការប្រើប្រាស់តុលាការធ្វើជាឧបករណ៍ណាមួយនោះ។ អ្នកជំនាញដែលបានស្នើឡើងដោយលោក ខៀវ សំផន អាចត្រូវបានកោះហៅក្នុងឋានៈជាជនដែលពុំមែនជាភាគីនៃរឿងក្តី ដោយហេតុថា ពួកគេត្រូវបានមនុស្សទូទៅស្គាល់ច្បាស់ ហើយមានបទពិសោធន៍ទូលំទូលាយផ្នែកនីតិព្រហ្មទណ្ឌអន្តរជាតិ នីតិទំនាក់ទំនងអន្តរជាតិ និងនីតិមនុស្សធម៌។

១០. កំណត់សម្គាល់អស់ទាំងនេះត្រូវបានធ្វើឡើង ដើម្បីធានាឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ និងមានប្រសិទ្ធិភាព ក្នុងកិច្ចស្វែងរកការពិតសម្រាប់សហគមន៍អន្តរជាតិ និងប្រជាជនកម្ពុជា។

## ហេតុដូច្នេះ

១១. លោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

---

លេញទៅលើសាក្សីទាំងនោះ ប្រសិនណាជាពួកគេត្រូវតម្រូវឲ្យមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនោះ។

[6] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427។

[7] ដីកា កថាខណ្ឌ៦ ៣) និងឧបសម្ព័ន្ធ ១។

- **សម្រេចថា** ការអនុវត្តវិធាន ៨០ នៃវិធានផ្ទៃក្នុង បានរំលោភលើគោលការណ៍សច្ចាធារណ៍និរទោសរបស់លោក ខៀវ សំផន ដែលតាមរយៈគោលការណ៍នេះ បន្ទុកនៃភស្តុតាងធ្លាក់ទៅលើអយ្យការ បានរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវពេលវេលា និងលក្ខណៈគ្រប់គ្រាន់ សម្រាប់ត្រៀមរៀបចំការពារខ្លួនប្រកបដោយសមភាពពេញលេញ ដោយធៀបទៅនឹងសេវា និងបែបផែនការងាររបស់សហព្រះរាជអាជ្ញា ក៏ដូចជាបានរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការកាត់សេចក្តីដោយមិនយឺតយ៉ាវហួសហេតុផងដែរ។

- **ទទួល** យកព័ត៌មានស្តីអំពីសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយលោក ខៀវ សំផន ហើយដែលព័ត៌មានទាំងនោះត្រូវបានដាក់ក្នុងពេលនេះតែម្តង។

- **អនុញ្ញាត** ឲ្យលោក ខៀវ សំផន ធ្វើការកែប្រែនៅពេលក្រោយ នូវបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ រួមទាំងអត្ថបទអង្គហេតុសង្ខេបដែលសាក្សីនីមួយៗត្រូវដាក់ អត្ថបទសង្ខេបរបស់អ្នកជំនាញដែលបានស្នើឡើង ក៏ដូចជាចំណុចទាំងឡាយនៃដីកាបញ្ជូនរឿងទៅជម្រះ ដែលពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សី និងចម្លើយរបស់អ្នកជំនាញនីមួយៗ។

- **ប្រកាស និងសម្រេចថា** វាជាករណីចាំបាច់ដែលត្រូវជ្រើសតាំងជនដែលពុំមែនជាភាគីនៃរឿងក្តី ពីក្នុងចំណោមបញ្ជីឈ្មោះអ្នកជំនាញដែលបានស្នើឡើង ឬក៏ឥស្សរជនដទៃទៀតដែលត្រូវបានទទួលស្គាល់លើឆាកអន្តរជាតិថាមានបទពិសោធន៍ខាងផ្នែកនីតិព្រហ្មទណ្ឌអន្តរជាតិ ខាងប្រវត្តិសាស្ត្រ ខាងនីតិ និងទំនាក់ទំនងអន្តរជាតិ ខាងទស្សនវិជ្ជា និងខាងសិទ្ធិមនុស្ស។

**រក្សាសិទ្ធិគ្រប់យ៉ាង**

## និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី សរ សូវាន<br><br>មេធាវី Jacques VERGÈS<br><br>មេធាវី Philippe GRECIANO | ភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |